# សិលាចារឹកវត្តមៀន K.១០៥ (ភាគ១)

ស្របគ្នានឹងការសិក្សាសិលាចារឹកដែលរកឃើញថ្មីៗជាបន្តបន្ទាប់ ការត្រឡប់ទៅពិនិត្យសើរើដើម្បីសិក្សាឡើងវិញ នូវសិលាចារឹកដែលធ្លាប់បោះពុម្ពដោយអ្នកស្រាវជ្រាវបរទេសរួចមកនោះ ក៏ជារឿងចាំបាច់ផងដែរ។ ឯកសារជាភាសាបរទេស គឺជារនាំងដល់សិស្សនិស្សិត និងសាធារណជនខ្មែរមួយចំនួន ដើម្បីស្វែងយល់អំពីសង្គម ប្រវត្តិសាស្ត្រ សាសនា ភាសា... នាសម័យបុរាណ តាមរយៈអត្ថបទសិលាចារឹក។ ម្យ៉ាងវិញទៀត ការពិនិត្យឡើងវិញនេះ អាចឱ្យយើងផ្ទៀងផ្ទាត់ និងបំពេញបន្ថែមលើឯកសារដែលមានកន្លងមកផង។ ហេតុដូច្នេះហើយ ទើបការរៀបចំអត្ថបទឬសៀវភៅជាភាសាខ្មែរ មានសារៈសំខាន់ដែលគួរតែធ្វើជារឿយៗ រហូតដល់មានឯកសារជាមូលដ្ឋានគ្រប់គ្រាន់ ដែលជាកាំជណ្ដើរសម្រាប់ជាន់ឡើងទៅមុខជាលំដាប់។

នៅក្នុងអត្ថបទនេះ យើងនឹងលើកយកសិលាចារឹកវត្តមៀនមកសិក្សាជាថ្មីម្តងទៀត ដ្បិតសិលាចារឹកនេះ មានបញ្ហាចំណោទលើអំណានកាលបរិច្ឆេទ និងវាក្យសព្ទមួយចំនួន ដែលត្រូវពិនិត្យឡើងវិញ ព្រមទាំងមានស្ថាននាមដែលត្រូវសិក្សាបន្ថែមផងដែរ។

## ព័ត៌មានអំពីបុរាណដ្ឋាន

វត្តមៀន មានទីតាំងនៅខាងត្បូងបឹងក្រពិត[១] ស្ថិតក្នុងភូមិមៀន ឃុំមៀន ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ។ នៅក្នុងបរិវេណវត្តនេះ មានទីតាំងប្រាសាទបុរាណមួយ ដែលបច្ចុប្បន្នបានបាត់រូបរាងទាំងស្រុងទៅហើយ នៅសល់តែសំណល់បុរាណវត្ថុមួយចំនួនប៉ុណ្ណោះ។ បុរាណដ្ឋាននេះ ស្ថិតនៅភាគខាងត្បូងនៃខេត្តត្បូងឃ្មុំ នៅជាប់ព្រំប្រទល់ខេត្តព្រៃវែង និងខេត្តកំពង់ចាម។

ទីតាំងស្ថានីយ៍បុរាណវិទ្យាមួយនេះ ចុះលេខ IK. ១១៥ ក្នុងបញ្ជីប្រាសាទបុរាណខ្មែររបស់លោក លុយណេត៍ ដឺឡាហ្សុងគីយែរ។ ពុំមានឯកសារដែលនិយាយលម្អិតអំពីទីតាំងប្រាសាទនេះទេ មានតែការរៀបរាប់ខ្លីៗប៉ុណ្ណោះ។ អតីតប្រាសាទវត្តមៀននេះ ជាប្រាសាទដែលមានជាប្រាង្គឥដ្ឋបាក់បែកមួយ មានរាងបួនជ្រុងស្មើ បែរមុខទៅទិសខាង

---

[១] តាមលោក លុយណេត៍ ដឺឡាហ្សុងគីយែរ បឹងនោះឈ្មោះថា «បឹងព្រះពិត»។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

កើត មានកសិន្ធុទឹកព័ទ្ធជុំវិញ និងមានល្បើក[២]ឬបារាយណ៍ទឹកមួយ នៅទិសខាងកើត។[៣] បច្ចុប្បន្ន អ្នកស្រុកហៅល្បើកនេះថា «បឹង» ដែលមានទទឹងប្រហែល១២០ម៉ែត្រ និងបណ្ដោយប្រហែល២០០ម៉ែត្រ[៤] និងបានក្លាយទៅជាស្រែរបស់ប្រជាពលរដ្ឋដែលជាអតីតចៅអធិការវត្តនេះទៅហើយ។ ជាទូទៅ យើងសង្កេតឃើញថាប្រាសាទដែលមានសហគមន៍មនុស្សរស់នៅច្រើន តែងមានបារាយណ៍ទឹកមួយនៅខាងមុខ[៥] ដ្បិតជានិមិត្តរូបផង និងសម្រាប់ផ្គត់ផ្គង់ដល់ប្រជាជនផង។ ដូច្នេះហើយ ទីតាំងនេះ ទំនងជាទីប្រជុំជនសំខាន់មួយដែលស្ថិតនៅក្នុងវិសាលភាពនៃរាជធានីឥន្ទ្របុរ ដែលយោងតាមសិលាចារឹកស្ដុកកក់ធំ ឥន្ទ្របុរ គឺជាទីតាំងដំបូងដែលព្រះបាទស្រីជ័យវរ្ម័ទេវទី២ មកគ្រប់គ្រងក្រោយពេលទ្រង់ត្រឡប់មកអំពីជវា។

នៅឆ្នាំ២០០៣ មានសំណង់ថ្មីកសាងពីបេតុង រចនារូបរាងជាប្រាសាទ ហៅឈ្មោះថា «ប្រាសាទព្រះវិហារគុក» ឬហៅខ្លីថា «វិហារគុក»។ បច្ចុប្បន្ន នៅទីនេះ ឃើញមានសំណល់បុរាណវត្ថុមួយចំនួនដូចជា៖ ថ្មទ្រនាប់ជណ្ដើរសាងពីថ្មបាសាល់ ថ្មបាយក្រៀម បំណែកផ្ដែរមួយផ្ទាំង ជើងទម្រចំនួន២[៦] បន្ទះថ្មស្នានទ្រោនី មេទ្វារប្រាសាទចំនួនពីរ ដែលមេទ្វារមួយមានសិលាចារឹក K.១០៥ នេះ។ បំណែកផ្ដែរដែលនៅសល់ អាចឱ្យយើងដឹងថាផ្ដែរនេះ ស្ថិតនៅអន្តរកាល រវាងរចនាបថបាខែង និងរចនាបថកោះកេរ នៅរវាងចុងស.វ. ទី៩និងដើមស.វ.ទី១០[៧]។ សិលាចារឹកវត្តមៀននេះ ក៏មានចុះកាលបរិច្ឆេទរំលឹកដល់ព្រឹត្តិការណ៍នាមហាសករាជឆ្នាំ៨៣៤ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩១២ ដែលមានលក្ខណៈស្រប

---

[២] ពាក្យ «ល្បើក» បង្កើតមកពីពាក្យឫស «លើក» ដែលហៅសំដៅដល់ប្រព័ន្ធធារាសាស្ត្រ ដែលកើតចេញពីការជីកលើកដីជាខ្នងទំនប់ដើម្បីទប់ទឹក។

[៣] អែម៉ូនីញេរ (១៩០០), លុយណេត៍ ដឺឡាហ្សុងគីយែរ (១៩០២) និង CISARK។

[៤] រង្វាស់ប្រវែងនេះ វាស់នៅក្នុងកម្មវិធី Google Earth។

[៥] វង់ សុធារ៉ា, ២០១២៖ ៨៧។

[៦] លោក លុយណេត៍ ដឺឡាហ្សុងគីយែរ បានរៀបរាប់ថាមានបល្ល័ង្កដ៏ស្រស់ស្អាតមួយ ដែលមានឆ្លាក់រូបគ្រុឌ ប៉ុន្តែបច្ចុប្បន្នពុំឃើញមាននៅទីនោះទៀតទេ។

[៧] កំណត់រចនាបថនិងអាយុកាលដោយ លោក ឡេង ស៊ីវ៉េង បេក្ខជនបណ្ឌិតផ្នែកប្រវត្តិសិល្បៈខ្មែរ នៅសាកលវិទ្យាល័យសិល្បករ ប្រទេសថៃ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

គ្មានឹងផ្តេរ និងនាំឱ្យយើងអាចយល់បានថាបុរាណដ្ឋាននេះ យ៉ាងហោចណាស់ក៏បន្សល់តាំងពីរវាងដើមស.វ.ទី១០មកម្ល៉េះ។ យ៉ាងនេះក្តី ថ្មទ្រនាប់ជណ្តើរសាងពីថ្មបាសាល់ដែលភាគច្រើននិយមប្រើក្នុងសម័យមុនអង្គរ នៅតំបន់ខេត្តកំពង់ចាម ជាទីដែលមានប្រភពថ្មនេះ ក៏អាចឱ្យយើងយល់បានថា នៅទីតាំងប្រាសាទវត្តមៀននេះ អាចមានអត្ថិភាព តាំងពីសម័យមុនអង្គរមក និងកសាងបន្ថែមនៅសម័យអង្គរ។ ជាការសោកស្តាយ ដែលពុំមានកំណាយបុរាណវិទ្យា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ពីអាយុកាលចំណាស់របស់ទីតាំងនេះបាន។

## ប្រវត្តិនៃការសិក្សាសិលាចារឹក

អ្នកស្រាវជ្រាវជាតិបារាំង ចាប់ផ្តើមសិក្សាអំពីប្រាសាទ និងសិលាចារឹកវត្តមៀនតាំងពីឆ្នាំ១៩០០មកម្ល៉េះ។ លោក អែម៉ូនីញេរ៍ បានរៀបរាប់អំពីទីតាំងប្រាសាទ និងសិលាចារឹក ព្រមទាំងសង្ខេបអត្ថន័យរបស់សិលាចារឹកនេះផង ចុះផ្សាយនៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា «ប្រទេសកម្ពុជា ភាគទី១ (Le Cambodge I)» នៅទំព័រទី២៨២។ ចំណែកនៅក្នុងសៀវភៅ «បញ្ជីសារពើភណ្ឌពិពណ៌នានៃប្រាសាទប្រទេសកម្ពុជា ភាគទី១ (Inventaire Descriptif des Monuments du Cambodge, Tome 1)» ទំព័រ១៥៥ វិញ លោក លុយណេត៍ ដឺ ឡាហ្សុងគីយែរ បានរៀបរាប់បន្ថែមអំពីប្រាសាទវត្តមៀន និងរំឭកពីសិលាចារឹកនៅប្រាសាទនេះបន្តិចបន្តួចប៉ុណ្ណោះ។ បន្ទាប់មកទៀត នៅឆ្នាំ១៩៥៤ លោក ហ្សក សឺដេស បានសិក្សាអត្ថបទសិលាចារឹកនេះ ដោយចម្លងអត្ថបទជាអក្សរឡាតាំង បកប្រែជាភាសាបារាំង ចុះផ្សាយនៅក្នុងកម្រងស្នាដៃសៀវភៅ «សិលាចារឹកនៃប្រទេសកម្ពុជា ភាគទី៦ (Inscription du Cambodge Volume 6)»។ ការដែលយកសិលាចារឹកនេះមកសិក្សាឡើងវិញ លោកបានកែតម្រូវកំហុសមួយចំនួនរបស់លោក អែម៉ូនីញេរ៍ ទាក់ទងនឹងផ្នែកនរនាមនិងស្ថាននាមឱ្យបានត្រឹមត្រូវតាមអត្ថបទចារឹកឡើងវិញ។ ចុងក្រោយ យើងឃើញលោក ហ្វីលីព ជេនឺរ៍ បានសិក្សាសិលាចារឹកវត្តមៀននេះឡើងវិញ ចុះផ្សាយជាភាសាអង់គ្លេស នៅលើគេហទំព័រ sealang.net ដែលការសិក្សានោះពឹងផ្អែកលើសៀវភៅរបស់លោក ហ្សក សឺដេស និងឯកសារមុនៗដែលបានរៀបរាប់។ ការសិក្សារបស់លោកក៏បានកែសម្រួលអំណានខ្លះៗ បន្ថែមលើអំណានរបស់អ្នកសិក្សាកន្លងមក។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

## ព័ត៌មាននិងអត្ថន័យសិលាចារឹក

សិលាចារឹកភូមិមៀន ចុះលេខបញ្ជីសារពើភណ្ឌសិលាចារឹកខ្មែរ K.១០៥ ចារលើមេទ្វារសាងពីថ្មភក់ ដែលបច្ចុប្បន្នមានសភាពសឹករេចរឹល របេះថ្មដោយអន្ទើ។ មេទ្វារនេះតម្កល់ដោយចាក់ភ្ជាប់នឹងបល្ល័ង្កព្រះពុទ្ធរូប ជ្រុងខាងត្បូង ក្នុងបរិវេណប្រាសាទព្រះវិហារគុហ៍ និងចុះបញ្ជីសារពើភណ្ឌបុរាណវត្ថុរបស់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្តត្បូងឃ្មុំ លេខ PVK-២០១៨-០០៣ ដោយ ។ អត្ថបទទាំងមូល ចារជាភាសាខ្មែរបុរាណ ដែលអាចចែកជា៣ផ្នែកផ្សេងគ្នា សរុបមានចំនួន ៣០បន្ទាត់។ អត្ថបទនីមួយៗ មានបង្ហាញពីកាលបរិច្ឆេទនាស.វ.ទី៩និងទី១០។

**អត្ថបទផ្នែកទី១៖** មាន១៦បន្ទាត់ ចុះកាលបរិច្ឆេទមហាសករាជឆ្នាំ៨៣៤ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩១២។

**អត្ថបទផ្នែកទី២៖** មាន៤បន្ទាត់ ចុះកាលបរិច្ឆេទមហាសករាជឆ្នាំ៩០៨ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៨៦។

**អត្ថបទផ្នែកទី៣៖** មាន៨បន្ទាត់ ចុះកាលបរិច្ឆេទមហាសករាជឆ្នាំ៩០៩ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៨៧។

នៅក្នុងអត្ថបទចារឹកផ្នែកទី១ អ្នកស្រាវជ្រាវដែលបានសិក្សាសិលាចារឹកនេះកន្លងមក មានភាពស្រពិចស្រពិលត្រង់តួលេខទីពីរ ដ្បិតផ្នែកលើក្រដាសផ្តិត មិនអាចកំណត់បានច្បាស់ថាជាលេខ ២ ឬ ៣។ ដោយហេតុដូច្នេះហើយ ទើបលោក អែម៉ូនីញេរ លោកសឺដេស និងលោក ជេន្នើរ ស្នើកាលបរិច្ឆេទនេះថាអាចមានលទ្ធភាពអានបានពីរយ៉ាង គឺមហាសករាជឆ្នាំ៨២៤ ឬ ៨៣៤។ ប៉ុន្តែតាមរយៈការពិនិត្យលើថ្មផ្ទាល់ អាចឱ្យយើងឃើញយ៉ាងច្បាស់ថាតួលេខនោះ គឺជាលេខ ៣ ពុំមែនជាតួលេខ ២ នោះទេ។ យើងអាចសម្គាល់តួសញ្ញាលេខ២ និងលេខ៣ ដោយសារខ្សែកោងពាក់កណ្តាលរង្វង់(/ក្បូច)នៅផ្នែកខាងស្តាំនៃតួលេខទាំងពីរនេះ។ លេខ ២ មានខ្សែកោងពាក់កណ្តាលរង្វង់ចំនួនពីរ ចំណែកលេខ ៣ មានចំនួនបី។ រូបរាងតួលេខនៅលើសិលាចារឹកនេះ មានខ្សែកោងនោះចំនួនបីដង ដែលបង្ហាញយ៉ាងច្បាស់ថាជាលេខ ៣ ដោយឥតមានអ្វីជាមន្ទិលសង្ស័យទៀតនោះឡើយ។ ដូច្នេះកាលបរិច្ឆេទនេះ គឺមហាសករាជឆ្នាំ ៨៣៤ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ៩១២ ដែល

សាច់រឿងនេះ ស្ថិតនៅក្នុងរាជ្យព្រះបាទស្រីហស៌វរ្ម័ទេវទី១ (គ.ស.៩១០-៩២៥)។ ចំណែកឯអត្ថបទផ្នែកទីពីរនិងទីបី ចុះកាលបរិច្ឆេទនៅគ្រិស្តសករាជឆ្នាំ ៩៨៦ និង ៩៨៧ ដែលស្ថិតនៅក្នុងរាជ្យព្រះបាទស្រីជ័យវរ្ម័ទេវទី៥(គ.ស.៩៦៨-១០០១)។ តាមរយៈកាលបរិច្ឆេទ និងទម្រង់តួអក្សរ សិលាចារឹកនេះចារឡើងនៅអំឡុងចុងស.វ.ទី១០ និងដើមស.វ.ទី១១ ក្នុងរាជ្យព្រះបាទស្រីជ័យវរ្ម័ទេវទី៥។ ការចារអត្ថបទនេះ មានពីរដំណាក់កាលផ្សេងគ្នា។ ដំណាក់កាលទីមួយ គឺចារអត្ថបទផ្នែកទី១ និងដំណាក់កាលទីពីរ គឺចារអត្ថបទផ្នែកទី២ និងទី៣។ អត្ថបទផ្នែកទី១ ចារឡើងនៅក្រោយកាលបរិច្ឆេទដែលបានចុះនៅលើនោះ ពោលគឺជាអត្ថបទដែលចាររំលឹកអំពីហេតុការណ៍ដែលបានកើតឡើងរួចមកហើយ។

ចំពោះអត្ថន័យសិលាចារឹកវិញ នៅក្នុងអត្ថបទទី១ ផ្តើមឡើងដោយចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៨៣៤។ នៅឆ្នាំនោះ មានព្រះរាជបន្ទូលពីព្រះមហាក្សត្រ ត្រាស់បង្គាប់ដល់ម្រតាញស្រីវិក្រមសន្នាហ ទៅស្ថាបនាបដិមាព្រះនៅស្រុកទៃ នៅព្រៃវ្យក ខេត្តស្រីឥន្ទ្របូរ។ មន្ត្រីរូបនេះ និងម្រតាញខ្លោញមហាបុរស បានថ្វាយនូវទ្រព្យ ខ្ញុំបម្រើ ដី និងស្រែចំពោះព្រះ។ សេចក្តីចុងក្រោយ គឺជាបញ្ញត្តិហាមប្រាម និងដាក់ទោសទណ្ឌដល់នរណាដែលយកព្រះតង្វាយនឹងត្រូវកាប់ក្បាល។

អត្ថបទទី២ ចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៩០៨ (គ.ស. ៩៨៦)។ នៅឆ្នាំនោះ មានព្រះរាជបន្ទូលពីព្រះមហាក្សត្រ[៨] ទៅដល់វាបហប្ទ័យសិវៈដែលជារាជបម្រើប្រចាំការថ្នាក់ទី៤ ឱ្យមកធ្វើតង្វាយជាដីស្រែ ចំពោះប្រាសាទព្រះគម្តែងអញកគវតី។ ដីស្រែដែលត្រូវឱ្យនោះ ជាថ្លៃសងនឹងការបុលក្របី១នឹម ដើម្បីទិញថ្មបាយក្រៀមមកសាងប្រាសាទ។ វាបសិបជាខ្លោញឈ្នួល(មេឈ្នួល) មន្ត្រីទសាធិក្រឹត្ត និងរាជមន្ត្រី ជាអ្នកថ្វាយស្រែចំពោះទេពស្រីអង្គនោះ ជំនួសវាបហប្ទ័យសិវៈ។

ចំណែកឯអត្ថបទទី៣វិញ មានចុះកាលបរិច្ឆេទមហាសករាជឆ្នាំ៩០៩ (គ.ស.៩៨៦) គឺជាបញ្ជីអត្ថបទដែលរៀបរាប់ឈ្មោះអ្នកបម្រើប្រាសាទ ដែលខ្លោញពល និងខ្លោញវិស័យក្នុំកន្សែង ថ្វាយចំពោះទេពស្រីនៃប្រាសាទព្រះគម្តែងអញកគវតី។ នៅក្នុងនោះ ក៏មានរៀបរាប់ពីរបៀបដែលទិញខ្ញុំបម្រើទាំងនោះផងដែរ។

---

[៨] កាលបរិច្ឆេទនេះ ត្រូវនឹងព្រះបាទស្រីជ័យវរ្ម័ទេវទី៥ (គ.ស.៩៦៨-១០០១)។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ឯកសារពិគ្រោះ

វង់ សុធារ៉ា (២០១២) សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល, បោះពុម្ពលើកទី២ (គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត)

Aymonier, E. (1904). *Le Cambodge I : Le Royaume Actuel*. E. Leroux.

Cœdès, G. (1954). Piédroit de Phum Mien (K. 105) in *Inscriptions du Cambodge*, Vol. 6. Paris.

de Lajonquière, É. E. L. (1902). *Inventaire descriptif des monuments du Cambodge* (Vol. 1). E. Leroux.

CISARK: https://cisark.mcfa.gov.kh/core/showsite.php?id=156

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

# បញ្ជីរូបភាព




ផែនទីវត្តមៀន (រូបថត៖ Google Earth)



ប្រាសាទព្រះវិហារគុហ៍ ទីតម្កល់សិលាចារឹកវត្តមៀន (រូបថត ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



អ្នកស្រុកមកសូត្រធម៌ជារៀងរាល់ថ្ងៃ អំឡុងពេលចូលវស្សា (រូបថត ហ៊ិន ឈុនតេង)



បរិវេណខាងក្នុងប្រាសាទព្រះវិហារគុហ៍ ទីតម្កល់សិលាចារឹកវត្តមៀន (រូបថត ហ៊ិន ឈុនតេង)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង




សំណល់ផ្តែរប្រាសាទ (រូបថត ហ៊ុន ឈុនតេង)



សំណល់ផ្តែរប្រាសាទ (រូបថត ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ថ្មទ្រនាប់ជណ្ដើរសាងពីថ្មបាសាល់ (រូបថត ហ៊ុន ឈុនតេង)



ជើងទម្រសាងពីថ្មភក់ (រូបថត ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ជើងទម្រនិងបន្ទះស្នានទ្រានី (រូបថត ហ៊ុន ឈុនតេង)



សិលាចារឹកវត្តមៀន (រូបថត ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកវត្តមៀន (រូបថត EFEO_CAM16781)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកវត្តមៀន (រូបថត EFEO_CAM16782)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង